# ការណែនាំ ស្តីពីរេដបូក និងយុទ្ធសាស្ត្ររេដបូកជាត

## សេចក្តីព្រាងលើកទី ៤

**ដោយ ជា ណារ៉េត**

កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិ ស្តីពីយុទ្ធសាស្ត្ររេដបូកជាតិ
សៀមរាប ថ្ងៃទី២៩ ដល់៣០ ខែកញ្ញា ឆ្នាំ២០១៥

# មាតិកា

- អ្វីទៅជាវេជបូក ?
- ហេតុអ្វីត្រូវការវេជបូក ?
- ការអនុវត្តវេជបូកនៅកម្ពុជា
- អ្វីទៅជាយុទ្ធសាស្រ្តវេជបូកជាតិ ?

# ការបាត់បង់ និងរេចរឹលព្រៃឈើ

## កម្រិតអន្តរជាតិ

ការបាត់បង់ព្រៃឈើ = **13 លាន ហិកតា/ឆ្នាំ**

= 3561 ហិកតា/ ថ្ងៃ



**X 150**

**Per hour**

## ការប្រែប្រួលព្រៃឈើនៅអាស៊ី




**1990-2010**

**ការប្រែប្រួលប្រចាំឆ្នាំតំបន់ព្រៃឈើ**

Source : FAO, 2010, Global Forest Resources Assessment 2010





# រេដបូក ( REDD+ )

- គឺជាយន្តការអន្តរជាតិមួយសម្រាប់ជួយបញ្ឈប់ការបាត់បង់ព្រៃឈើ និងការប្រែប្រួលអាកាសធាតុ។

- គឺជាការផ្តល់នូវហិរញ្ញប្បទាន ដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ធ្វើការកាត់បន្ថយការបំភាយឧស្ម័នដែលបណ្តាលមកពីការបាត់បង់និងរេចរឹលព្រៃឈើ។

# រេដបូក( REDD+ )

ការកាត់បន្ថយការបំភាយឧស្ម័នដែលបណ្តាលមកពីការបាត់បង់ និងរេចរឹលព្រៃឈើ

Reducing Emission from Deforestation and Forest Degradation

**R** educing ( ការកាត់បន្ថយ )

**E** mission ( ការបំភាយឧស្ម័ន )

**D** eforestation ( ការបាត់បង់ព្រៃឈើ )

**D** egradation ( ការរេចរឹលព្រៃឈើ )

**+**

+ ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព

+ ការអភិរក្សព្រៃឈើ

+ ការបង្កើនបរិមាណកាបូនស្តុក

# អ្វីទៅជាយន្តការរេដបូក?

ប្រទេសកំពុងអភិវឌ្ឍ ដើម្បីរក្សាកាបូនដែលមានក្នុងព្រៃ




ដើម្បីទូទាត់ការកាត់<u>បន្ថយការបំភាយ</u> ឧស្ម័នរបស់ខ្លួន












# សកម្មភាពដែលស្ថិតក្រោមការអនុវត្តរេដបូក

១. កាត់បន្ថយការបំភាយឧស្ម័នដែលចេញ ពី ការបាត់បង់ព្រៃឈើ ?





# ២. កាត់បន្ថយការបំភាយ ឧស្ម័នដែលចេញពី ការរេចរឹលព្រៃឈើ ?











# អភិរក្សតំបន់ព្រៃឈើ និងជាតំបន់សក្តានុពល




+

# ដាំឈើបន្ថែម





# ប្រើប្រាស់ព្រៃឈើរបស់ខ្លួនអោយមាននិរន្តភាព





# ហេតុអ្វីត្រូវការ REDD+ ?

- ការប្រែប្រួលអាកាសធាតុកាន់តែមានឥទ្ធិពលខ្លាំងមកលើផែនដី











- ព្រៃឈើជាអាងស្តុកឧស្ម័ន និងក៏ជាភ្នាក់ងារបំភាយឧស្ម័ន
- ពី១៥ទៅ២០% នៃការបំភាយឧស្ម័នទៅបរិយាកាស គឺបណ្តាលមកពីការបាត់បង់ និងរេចរឹលព្រៃឈើ



# ហេតុអ្វីត្រូវការ REDD+ ?

- ព្រៃឈើមានមុខងារជួយការពារ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

- ផ្តល់ការលើកទឹកចិត្តដល់ការកាត់បន្ថយការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើតាមរយៈការលក់ឥណទានកាបូន។



# ហេតុអ្វីត្រូវការ REDD+ ?

- ផ្ទៃដីព្រៃឈើលើពិភពលោក ៣៩៥២ លានហិកតា (៣០%នៃផ្ទៃដីសរុប)

- ការបាត់បង់ព្រៃឈើលើពិភពលោក ១៣លានហិកតា/ឆ្នាំ






# ការអនុវត្តរេដបូកនៅប្រទេសកម្ពុជា

ការអនុវត្តរេដបូកកម្រិតជាតិ



ការអនុវត្តរេដបូកកម្រិតគម្រោង









# ការអនុវត្តកម្រិតថ្នាក់ជាតិ និងអន្តរជាតិ

ដោះស្រាយការប្រែប្រួលអាកាសធាតុ ⟷ ការប្រែប្រួលដី និងព្រៃឈើ រួមទាំង **រេដបូក**



កិច្ចប្រជុំប្រទេសជាភាគីក្រោម អនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) រៀងរាល់ **ខែធ្នូ**

# តំណាក់កាលនៃការអនុវត្តវេជបូកនៅក្នុងប្រទេសកម្ពុជា

**តំណាក់ទី១៖** ការត្រៀមលក្ខណៈរៀបចំគោលនយោបាយ និងយុទ្ធសាស្រ្ត (២០១២- ២០១៥)

**តំណាក់ទី២៖** ការអនុវត្តគោលនយោបាយ និងវិធាននានា (២០១៦-២០២០)

**តំណាក់ទី៣៖** ការទូទាត់ផ្អែកលើលទ្ធផល (២០២០)

# ការអនុវត្តរេដបូកនៅក្នុងប្រទេសកម្ពុជា៖ *កាលបរិច្ឆេទសំខាន់ៗ*

- **1995** គាំទ្រដល់អនុសញ្ញា UNFCCC
- **2002** ឯកភាពលើពិធីសារ Kyoto Protocol
- **2009** ក្លាយជាសមាជិកកម្មវិធី UN-REDD និងកម្មវិធីធនាគាពិភពលោក FCPF
- **2010** រៀបចំក្រុមការងាររេដបូកបណ្តោះអាសន្ន និងបានរៀបចំផែនទីបង្ហាញផ្លូវរេដបូក
- **2010** ចាប់ផ្តើមអនុវត្តផែនទីបង្ហាញផ្លូវក្រោមមូលនិធិ UN-REDD Programme
- **2012** បង្កើតក្រុមការងាររេដបូកជាផ្លូវការ ដែលមាន ៧ក្រសួងពាក់ព័ន្ធចូលរួម
- **2014** អនុវត្តផែនទីបង្ហាញផ្លូវក្រោមមូលនិធិកម្មវិធីធនាគារពិភពលោក FCPF
- **2015** រៀបចំយុទ្ធសាស្ត្ររេដបូកជាតិ, កម្រិតបំភាយយោង, ប្រព័ន្ធធានាសុវត្ថិភាពរេដបូក និងប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិ
- **2016** ចាប់ផ្តើមអនុវត្តន៍យុទ្ធសាស្ត្ររេដបូកជាតិ

# អ្វីទៅជា យុទ្ធសាស្ត្រ រេដបូកជាតិ ?

១. ជាឯកសារគោល ដើម្បីបង្ហាញពី យុទ្ធសាស្ត្រក្នុងការកាត់បន្ថយការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើ និងអភិវឌ្ឍន៍ជីវភាពសហគមន៍មូលដ្ឋាន

២. ឯកសារដើម្បីបង្ហាញផ្លូវដល់អ្នកពាក់ព័ន្ធ ក្នុងការចូលរួមអនុវត្តយន្តការរេដបូកនៅក្នុងប្រទេសកម្ពុជា

៣. ជាឧបករណ៍សម្រាប់ផ្តល់ការគាំទ្រហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍

៤. បំពេញនូវតម្រូវការ និងការចូលរួមអនុវត្តន៍រេដបូកជាសកល (កម្រិតជាតិ តំបន់ និងអន្តរជាតិ)



# អរគុណ !

# ការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងការរៀបចំ និងអនុវត្ត យុទ្ធសាស្ត្ររេដបូកជាតិ ?





# អ្វីទៅជា អ្នកពាក់ព័ន្ធ ?

ក្រុមដែលជាប់ពាក់ព័ន្ធ ចាប់អារម្មណ៍ រឺ សិទ្ធិ នៅក្នុងការគ្រប់គ្រងព្រៃឈើ និងអ្នកដែលនឹងទទួលរងឥទ្ធិពលទាំងវិជ្ជមាន និងអវិជ្ជមានដោយសកម្មភាពរេដបូក

<u>ក្រុមទាំងនោះរួមមាន៖</u>

- ស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ
- អ្នកប្រើប្រាស់ព្រៃឈើទាំងផ្លូវការ និងក្រៅផ្លូវការ (ស្ត្រី និងបុរស)
- វិស័យឯកជន
- សហគមន៍ក្រុមជនជាតិដើមភាគតិច(ស្ត្រី និងបុរស)
- សហគមន៍ដែលអាស្រ័យព្រៃឈើ
- សង្គមស៊ីវិល
- អ្នកពាក់ព័ន្ធផ្សេងទៀត



# ហេតុអ្វី ការភ្ជាប់អ្នកពាក់ព័ន្ធវាមានសារៈសំខាន់ការអនុវត្តយន្តការរេដបូក?





## ជាទូទៅ  រេដបូក  មានសក្តានុពល ជាច្រើន៖

- ធ្វើអោយប្រសើឡើងនូវការគ្រប់គ្រងព្រៃឈើ  អភិបាលកិច្ច  និងការពង្រឹងច្បាប់
- បង្កើតអោយមានឱកាសក្នុងការសម្រេចចិត្ត  ការគ្រប់គ្រងដោយសមធម៌ និងជឿជាក់





## *ជាទូទៅ   វេជបូក  មានសក្តានុពល ជាច្រើន(ត)៖*

- បង្កើនសន្តិសុខស្បៀងតាមរយៈការពង្រឹងជីវភាពរស់នៅជាលក្ខណៈប្រពៃណី  និងបង្កើនធនធានបន្ថែមសម្រាប់ជនជាតិដើមភាគតិច និងសហគមន៍ដែលពឹងពាក់អាស្រ័យព្រៃឈើ
- ភ្ជាប់វិស័យឯកជន អោយមានការសហការរវាងឯកជន និង សាធារណៈ ដើម្បីសម្រេចលទ្ធផលវេជបូក





*ប៉ុន្តែ  ក៏មានការភ័យខ្លាចមួយចំនួន ដែលអាចកើតចេញពីការអនុវត្តរេដបូក៖*

- ការបំលែងដីព្រៃធម្មជាតិទៅជាព្រៃដាំ
- អសមធម៌ក្នុងការចែករំលែងផលប្រយោជន៍
- ការទន្ទ្រានយក  ចាប់យកដី និងជំលោះដីធ្លី
- មានការទាញយកមូលនិធិ ដោយអ្នកមានអំណាច
- មិនមានភាពស្មើគ្នា ( ឧ. យេនឌ័រ )

*សម្រាប់ជនជាតិដើមភាគតិច និងសហគមន៍ដែលពឹងអាស្រ័យលើព្រៃឈើ៖*

- ត្រូវបានដកចេញពីការសម្រេចចិត្ត
- មិនអាចចូលទៅក្នុងព្រៃដើម្បីប្រមូលផល អនុផលព្រៃឈើ



# តួនាទីរបស់អ្នកពាក់ព័ន្ធនៅក្នុងការរៀបចំ និង អនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ



# ការភ្ជាប់អ្នកពាក់ព័ន្ធអំឡុងពេលរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ



# ការភ្ជាប់អ្នកពាក់ព័ន្ធអំឡុងពេលអនុវត្តយុទ្ធសាស្ត្រវេជបូកជាតិ



# អរគុណ!









# ការអនុវត្តរេដបូកនៅប្រទេសកម្ពុជា



ការអនុវត្តរេដបូកកម្រិតជាតិ

ការអនុវត្តរេដបូកកម្រិតគម្រោង









# តើតម្រូវការអ្វីខ្លះ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ដើម្បីទទួលបានការទូទាត់ផ្អែកលើលទ្ធផល ក្នុងការអនុវត្តរេដបូក?

កិច្ចប្រជុំប្រទេសជាភាគី លើកទី ១៩ នៃក្របខណ្ឌអនុសញ្ញាសហប្រជាជាតិ ស្តីពី ការប្រែប្រួលអាកាសធាតុ (UNFCCC

រៀបចំនៅទីក្រុង វ៉ែសវី ប្រទេសប៉ឡូញ - អនុម័តលើក្របខណ្ឌ

*ក្របខណ្ឌវ៉ែស វី សម្រាប់ការអនុវត្តរេដបូក*









# សេចក្តីសង្ខេប ស្តីពី យុទ្ធសាស្ត្ររេដបូកជាតិ

សេចក្តីព្រាងលើកទី ៤

កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិ ស្តីពីយុទ្ធសាស្ត្ររេដបូកជាតិ
សៀមរាប ថ្ងៃទី២៩ ដល់៣០ ខែកញ្ញា ឆ្នាំ២០១៥

# ឧបសគ្គដែលត្រូវដោះស្រាយក្រោមយន្តការរេដបូក







?






?






?



?




?



© Can Stock Photo - csp2017924

?



## ១. សេចក្ដីផ្ដើម

១.១ រេដបូកនៅកម្រិតអន្តរជាតិ

- សេចក្ដីសម្រេចរបស់ UNFCCC ទាក់ទងនឹងការអនុវត្តរេដបូក

១.២ រេដបូកនៅកម្ពុជា

- ដំណើការ និងបច្ចុប្បន្នភាពនៃការអនុវត្តរេដបូកនៅកម្ពុជា

## ២. ចក្ខុវិស័យ

កម្ពុជារួមចំណែកក្នុង**ការកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅកម្រិតជាតិ និងកម្រិតពិភពលោក** តាមរយៈការកែលម្អការអនុវត្តនៅក្នុងការ**គ្រប់គ្រងព្រៃឈើ ការអភិរក្សជីវចម្រុះ និងការអភិវឌ្ឍបៃតង។**



## ៣. បេសកកម្ម

ការកែលម្អមុខងារ និងសមត្ថភាពរបស់ស្ថាប័នគ្រប់គ្រងព្រៃឈើនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងស្ថាប័នពាក់ព័ន្ធរបស់ខ្លួន ដើម្បីពង្រឹងការអនុវត្តគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិនានាដែលមានស្រាប់ជាពិសេស ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ដើម្បីសម្រេចបានការអភិវឌ្ឍបៃតង និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ។



# ៤. គោលបំណង

1. កាត់បន្ថយការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ ទន្ទឹមនឹងការលើកកម្ពស់ការអភិវឌ្ឍប្រកប ដោយចីរភាព ការអភិរក្ស និងការបង្កើនកាបូនស្តុកព្រៃឈើ

2. បង្ហាញឲ្យឃើញថា រេដបូកអាចជាវិធានការមួយក្នុងចំណោមវិធានការនានា ដើម្បីកម្ពុជាប្តូរទៅរកលំនាំនៃការអភិវឌ្ឍបៃតង

3. លើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការចូលរួមនៅក្នុងសកម្មភាពកាត់បន្ថយការប្រែប្រួល អាកាសធាតុ ក្នុងវិស័យព្រៃឈើ

1. បំពេញតាមលក្ខខណ្ឌសម្រាប់កម្ពុជានៅក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ដើម្បីអាចទទួលបានការទូទាត់ផ្អែកតាមលទ្ធផល សម្រាប់ការអនុវត្តគោលនយោបាយរេដបូក និងវិធានការនានា។



# ៥. ក្របខណ្ឌយុទ្ធសាស្ត្រ

## ការវិភាគជាយុទ្ធសាស្ត្រ

- ការបន្ស៊ីជាមួយគោលបំណង និងអាទិភាពដទៃទៀតនៃការអភិវឌ្ឍជាតិ
- ទិដ្ឋភាពរួមនៃការគ្រប់គ្រងដីព្រៃនៅកម្ពុជា
- កត្តាដែលពាក់ព័ន្ធការបាត់បង់និងការរេចរឹលព្រៃឈើនៅកម្ពុជា
- កត្តាដែលពាក់ព័ន្ធការបាត់បង់និងការរេចរឹលព្រៃឈើដែលជាអាទិភាព ដែលត្រូវដោះស្រាយតាមរយៈយុទ្ធសាស្ត្ររេដបូកជាតិ (២០១៦-២០២០)



## ៥.៣ គោលបំណងជាយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រ

- <u>គោលបំណងជាយុទ្ធសាស្ត្រ ១៖</u> កែលម្អប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានព្រៃឈើ។

- <u>គោលបំណងជាយុទ្ធសាស្ត្រ ២៖</u> លើកកម្ពស់ការប្រមូលផលព្រៃឈើដោយនិរន្តរភាព។

- <u>គោលបំណងជាយុទ្ធសាស្ត្រ ៣៖</u> ពង្រឹងសមត្ថភាពដើម្បីត្រួតពិនិត្យ និងតាមដានធនធានព្រៃឈើ។

- <u>គោលបំណងជាយុទ្ធសាស្ត្រ ៤៖</u> បង្កើនសមត្ថភាព ចំណេះដឹង ការយល់ដឹង និងលើកកំពស់ការចូលរួមរបស់អ្នកពាក់ព័ន្ធ និងផលប្រយោជន៍សម្រាប់អ្នកពាក់ព័ន្ធ



# ៦. សកម្មភាព រឺ តំណាក់កាលអនុវត្តយុទ្ធសាស្ត្រ

- នៅរយៈពេលខ្លីចំពោះមុខ (ឆ្នាំ ២០១៦)៖ ការរៀបចំផែនការសកម្មភាពរេដបូក
- នៅក្នុងរយៈពេលមធ្យម (ឆ្នាំ)៖ ការអនុវត្តផែនការសកម្មភាពរេដបូក ២០១៦-២០២០
- នៅក្នុងរយៈពេលវែង(ក្រោយឆ្នាំ ២០២០)៖ ដំណាក់កាលនៃទូទាត់ដែលផ្អែកលើលទ្ធផល



## ៦.២ ក្របខ័ណ្ឌរ៉ាស្សូរីសម្រាប់រេដបូក

- ប្រព័ន្ធព័ត៌មានសុវត្ថិភាពរេដបូក (SIS)
- ប្រព័ន្ធតាមដានព្រៃឈើជាតិ (NFMS)
  - ❖ កម្រិតបំភាយយោងព្រៃឈើ
  - ❖ សារពើភណ្ឌព្រៃឈើថ្នាក់ជាតិ
  - ❖ សារពើភណ្ឌផ្ទះកញ្ចក់ថ្នាក់ជាតិ
- កម្រិតបំភាយយោងសម្រាប់ព្រៃឈើ (FREL/ FRL)



## ៦.៣ ការចាត់ចែងស្ថាប័ន និងការសម្របសម្រួល

- ការចាត់ចែងស្ថាប័នដែលមានស្រាប់ ដែលត្រួតពិនិត្យលើការរៀបចំ យុទ្ធសាស្ត្ររេដបូកជាតិ (២០១១ -២០១៥)

- ការចាត់ចែងស្ថាប័នសម្រាប់ត្រួតពិនិត្យ និងអនុវត្តយុទ្ធសាស្ត្រ NRS (២០១៦- ២០២០) និង (២០២០ ដល់ ២០៣០?)
  - ➢ គណៈកម្មាធិការជាតិរេដបូក (NRC)
  - ➢ មុខងាររបស់គណៈកម្មាធិការជាតិរេដបូក



## ៧. ធនធានហិរញ្ញវត្ថុ

### ៧.១ វិធីសាស្រ្តៈ វិធីដែលផ្អែកលើមូលនិធិ

(Fund based approach -2016-2020)

- ការបង្កើតទីភ្នាក់ងារជាតិផ្តល់មូលនិធិរេដបូក (Agency)
- តួនាទីរបស់ទីភ្នាក់ងារជាតិផ្តល់មូលនិធិរេដបូក(Roles of Agency)

### ៧.២ គោលការណ៍នានា

### ៧.៣ យន្តការគណនេយ្យភាពរបស់ទីភ្នាក់ងារជាតិមូលនិធិរេដបូក

## ៨. ការតាមដាន និងវាយតម្លៃ

- គោលការណ៍នានា
- វិធីសាស្រ្ត
- ការគ្រប់គ្រង និងការចាត់ចែងស្ថាប័នសម្រាប់ការអនុវត្ត



# គោលបំណង និងសកម្មភាពជាយុទ្ធសាស្ត្រ
# នៃយុទ្ធសាស្ត្ររេដបូកជាតិ

សេចក្ដីព្រាងលើកទី ៤

កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិ ស្ដីពីយុទ្ធសាស្ត្ររេដបូកជាតិ
សៀមរាប ថ្ងៃទី២៩ ដល់៣០ ខែកញ្ញា ឆ្នាំ២០១៥

# កត្តាដែលបណ្ដាលអោយមានការបាត់បង់ព្រៃឈើ និងថយចុះនៃព្រៃឈើនៅក្នុងប្រទេសកម្ពុជា

| ប្រភេទ | កត្តានានាដែលត្រូវដោះស្រាយរវាងឆ្នាំ ២០១៦-២០២០ |
|---|---|
| ផ្ទាល់ | ១. ការបម្លែងដីព្រៃ (ដែលមានផែនការ)<br>ក. ការអភិវឌ្ឍសេដ្ឋកិច្ច/កសិកម្ម (ដូចជា សម្បទានដីសេដ្ឋកិច្ច)<br>ខ. ការតាំងទីលំនៅ និងដីកសិកម្ម (ដូចជា សម្បទានដីសង្គមកិច្ច)<br>គ. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ (ដូចជា ការសាងសង់ផ្លូវថ្នល់ ទំនប់)<br>ឃ. ការធ្វើអាជីវកម្មរ៉ែ<br>២. ការទន្ទ្រានយកដីព្រៃ(ដែលមិនមានផែនការ)<br>ក. ការជួញដូរដីធ្លី/ ការចាប់យកដីធ្លី<br>ខ. ការកាប់ឈើល្មើសច្បាប់<br>៣. ការប្រមូលផលពីព្រៃឈើដោយគ្មាននិរន្តរភាព |

# កត្តាដែលបណ្តាលអោយមានការបាត់បង់ព្រៃឈើ និងការថយចុះនៃព្រៃឈើនៅក្នុងប្រទេសកម្ពុជា (បន្ត)

| ប្រភេទ | កត្តានានាដែលត្រូវដោះស្រាយរវាងឆ្នាំ ២០១៦-២០២០ |
|---|---|
| ប្រយោល | • អភិបាលកិច្ចក្នុងវិស័យព្រៃឈើ និងវិស័យប្រើប្រាស់ដីនៅមានកម្រិត<br>• កង្វះការសម្របសម្រួលរវាងក្រសួងនានាលើការរៀបចំផែនការប្រើប្រាស់ដី<br>• ភាពក្រីក្រនៅជនបទ<br>• ការចូលរួមរបស់ក្រុមអ្នកពាក់ព័ន្ធមានកម្រិត<br>• កង្វះហិរញ្ញវត្ថុ/ធនធានមនុស្សសម្រាប់រយៈពេលវែងដើម្បីគាំទ្រដល់វិស័យព្រៃឈើ<br>• កង្វះខាតទិន្នន័យ និងវិធានគ្រប់គ្រាន់សម្រាប់បង្កើតវិធានការទប់ស្កាត់បទល្មើសព្រៃឈើឲ្យមានប្រសិទ្ធភាព |


ចក្ខុវិស័យ
បេសកកម្ម
គោលបំណង
គោលបំណងយុទ្ធសាស្ត្រ ១៖
កែលម្អប្រសិទ្ធភាពនៃការ
គ្រប់គ្រងធនធានព្រៃឈើ
គោលបំណងយុទ្ធសាស្ត្រ ២៖
ពង្រឹងសមត្ថភាពដើម្បីពិនិត្យ
តាមដានធនធានព្រៃឈើ
គោលបំណងយុទ្ធសាស្ត្រ ៣៖
លើកកម្ពស់ការប្រមូល
ផលព្រៃឈើប្រកបដោយ
និរន្តរភាព។
គោលបំណងយុទ្ធសាស្ត្រ ៤៖
យល់ដឹង និងលើកកម្ពស់ការចូល
រួមរបស់អ្នកពាក់ព័ន្ធ និងផល
ប្រយោជន៍សម្រាប់អ្នកពាក់ព័ន្ធ
កែលម្អប្រសិទ្ធភាពនៃការ
គ្រប់គ្រងធនធានព្រៃឈើ



# សកម្មភាពជាយុទ្ធសាស្ត្រនៃយុទ្ធសាស្ត្រ
# រេដបូកជាតិ ដើម្បីដោះស្រាយ
# ការបាត់បង់ និងរេចរឹលព្រៃឈើ









# គោលបំណងយុទ្ធសាស្ត្រ ១៖

# ធ្វើអោយទ្បើងនូវប្រសិទ្ធិភាពនៃការគ្រប់គ្រងធនធានព្រៃឈើ

១. លើកកម្ពស់ប្រសិទ្ធិភាពការធ្វើផែនការគ្រប់គ្រងតំបន់ទេសភាពព្រៃឈើ (គ្រប់ប្រភេទព្រៃ) នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

២. ជម្រុញកិច្ចការពារសុវត្ថិភាពកម្មសិទ្ធិដីធ្លី និងដីព្រៃឈើ និងការធ្វើចំណាត់ថ្នាក់ព្រៃឈើ/តំណត់តំបន់ បោះបង្គោលព្រំ និងចុះបញ្ជីការដីព្រៃដោយផ្អែកលើមុខងារប្រព័ន្ធអេកូឡូស៊ី និងសារៈ សំខាន់ (*ឧទាហរណ៍៖ បង្កើតតំបន់ព្រៃការពារថ្មី តំបន់ព្រៃការពារ តំបន់អភិរក្សព្រៃកោងកាងនិងព្រៃលិចទឹក ដោយផ្អែកលើតម្លៃជីវចម្រុះនិងសេវាកម្មបរិស្ថាន*

៣. លើកកម្ពស់ប្រសិទ្ធិភាពនៃការគ្រប់គ្រង និងការប្រើប្រាស់ ផលអនុផល និងដីព្រៃឈើប្រកបដោយនិរន្តរភាព។

៤. បន្ទុបន្ថយផលប៉ះពាល់សង្គម និងបរិស្ថាន ក្នុងវិស័យព្រៃឈើ
( ការអនុវត្ត និងរៀបចំ EIA...... )

៥. បន្តផ្អាកជាបណ្តោះអាសន្ននូវការអនុញ្ញាតផ្តល់សម្បទានដី សេដ្ឋកិច្ច និងត្រួតពិនិត្យស្ថានភាពសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ដើម្បីអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់ និង ការពង្រឹងសមត្ថភាពស្ថាប័នដើម្បីត្រួតពិនិត្យសម្បទានដីសេដ្ឋកិច្ច

៦. រួមចំណែកដល់ការធានាថាតួនាទី និងការទទួលខុសត្រូវមិនត្រួតជាន់ គ្នានៃក្របខ័ណ្ឌ ច្បាប់សម្រាប់ការគ្រប់គ្រងដី និងធនធានព្រៃឈើ

៧. ពង្រឹងការការងារគ្រប់គ្រងតំបន់អភិរក្ស តំបន់ការពារ ព្រៃឈើការពារ(ឧទា. តំបន់ព្រៃការពារ, តំបន់ការពារធម្មជាតិ និងតំបន់អភិរក្សព្រៃលិចទឹក និងព្រៃកោងកាង ...)

# <u>គោលបំណងយុទ្ធសាស្ត្រ ២៖</u>

## លើកកម្ពស់ការប្រមូលផលព្រៃឈើប្រកបដោយនិរន្តរភាព។

១. ពង្រីក និងពង្រឹកគ្រប់គ្រងព្រៃឈើដោយសហគមន៍មូលដ្ឋាន

*( ឧទាហរណ៍៖សហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ  សហគមន៍នេសាទ និងកម្មវិធីចុះបញ្ជីដីជនជាតិដើមភាគតិច )*

២. ជម្រុញការប្រមូលឈើប្រកបដោយនិរន្តរភាព និង ការធ្វើផែនការគ្រប់គ្រង

៣. ដោះស្រាយតម្រូវការ និងការផ្គត់ផ្គង់ឈើថាមពល

៤. ជម្រុះអោយមាននិរន្តរភាពនៃខ្សែសង្វាក់ផលិតកម្ម/ផ្គត់ផ្គង់ ដែលជៀសមិនអោយមានការបាត់បង់ព្រៃឈើ *(ជាពិសេសផ្តោតលើវិស័យឯកជន)*

៥. ដោះស្រាយឥទ្ធិពលជាអវិជ្ជមានលើ សង្គម និងបរិស្ថានដែលអាចកើតចេញពី ដំណើការប្រមូលឈើ (*វាយតម្លៃ និងជម្រុញអោយពហុ ប្រយោជន៍ដល់ សង្គម និងបរិស្ថាន*)

៦. ជម្រុញអោយមានជម្រើសផ្សេងៗគ្នា នៃការផ្គត់ផ្គង់ប្រភពឈើ ( *ពិសេសការដាំឈើពីវិស័យឯកជន*)

៧. ពង្រឹងអោយមានការដាំឈើ ស្តាព្រៃឈើ និង ការអនុវត្តរុក្ខវប្បកម្ម

# គោលបំណងជាយុទ្ធសាស្រ្ត ៣៖

## ពង្រឹងសមត្ថភាពដើម្បីត្រួតពិនិត្យតាមដានធនធានព្រៃឈើ

១. ពង្រឹងសមត្ថភាព និងបច្ចេកទេសរបស់ស្ថាប័នដើម្បីប្រមូល វិភាគ និង រាយការពីប្រព័ន្ធព័ត៌មានដីព្រៃឈើ និងដីសម្រាប់អភិវឌ្ឍន៍ផ្សេងទៀត

២. ពង្រឹងការអនុវត្តច្បាប់ព្រៃឈើ និងអភិបាលកិច្ច

៣. ពង្រឹងប្រព័ន្ធសម្រាប់គ្រប់គ្រងព័ត៌មានដីព្រៃឈើ និង ដីសម្រាប់អភិវឌ្ឍន៍ផ្សេងទៀត

# គោលបំណងជាយុទ្ធសាស្ត្រ ៤៖

**បង្កើនសមត្ថភាព ចំណេះដឹង ការយល់ដឹង និងលើកកំពស់ការចូលរួមរបស់អ្នកពាក់ព័ន្ធ និង ផលប្រយោជន៍សម្រាប់អ្នកពាក់ព័ន្ធកែលម្អប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានព្រៃឈើ**

១. ពង្រឹងស្ថាប័ន និងសម្របសម្រួលក្របខ័ណ្ឌការងារ លើការធ្វើផែនការប្រើប្រាស់ដីធ្លីសម្រាប់គម្រោងអភិវឌ្ឍ/ហេដ្ឋារចនាសម្ព័ន្ធទ្រង់ទ្រាយធំ។

២. បង្កើនសមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ការអនុវត្តគោលនយោបាយដើម្បីកាត់បន្ថយការបាត់បង់ព្រៃឈើ និង ការរិចរឹល ព្រៃឈើ

៣. លើកម្ពស់យន្តការសម្របសម្រួលស្ថាប័នសម្រាប់ការឆ្លើយតបគោលនយោបាយ ដើម្បីដោះស្រាយការបាត់បង់ព្រៃឈើ និងការរិចរឹលព្រៃឈើ

៤. ជម្រុញការអនុវត្តយុទ្ធសាស្ត្ររេជបូកជាតិដើម្បីបង្កើត ហិរញ្ញវត្ថុបន្ថែមក្នុងការគាំទ្រវិស័យព្រៃឈើ

៥.បញ្ជ្រាបយុទ្ធសាស្ត្ររេជបូកជាតិ ជាមួយគោល នយោបាយថ្នាក់ជាតិ និងលិខិតបទដ្ឋានច្បាប់គតិយុត្ត ផ្សេងៗដែលពាក់ព័ន្ធ

៦. ពង្រឹងតួនាទីរបស់គ្រឹះស្ថានសិក្សាស្រាវជ្រាវ ក្នុងការ បណ្តុះបណ្តាល ស្តីពីព្រៃឈើ និងរេជបូក

៧. បង្កើនការចូលរួមពីសាធារណៈជន និងការប្រឹក្សាយោបល់ជាចំណុច ជាតុសំខាន់សម្រាប់ការធ្វើផែនការគ្រប់គ្រងព្រៃឈើ និងការធ្វើផែនការ ប្រើប្រាស់ដីធ្លី

៨. គាំទ្រដល់សកម្មភាព និងកម្មវិធីបង្កើនជីវភាពសហគមន៍ និងជន ជាតិដើមភាគតិចដើម្បីកាត់បន្ថយសំពាធលើការប្រើប្រាស់ព្រៃឈើ

## អរគុណ !

# ក្របខ័ណ្ឌ និងប្រព័ន្ធព័ត៌មាន ធានាសុវត្ថិភាពរេដបូក (SIS)










PHOTOGRAPHERS
DIRECT.COM












# ហានិភ័យសង្គមសម្រាប់សហគមន៍ និង ជនជាតិដើមភាគតិចដែលពឹងពាក់លើព្រៃឈើ

## ផលប៉ះពាល់អវិជ្ជមានលើជីវភាពរស់នៅ



- ការហាមឃាត់ ឬ រឹតបន្តឹងលើការប្រើប្រាស់ព្រៃឈើ
- ការតាំងលំនៅថ្មីដែលមិនមានការស្ម័គ្រចិត្ត
  - ការបដិសេធមិនឲ្យចូលរួមក្នុងការធ្វើសេចក្ដីសម្រេចចិត្ត និងការបែងចែកផលប្រយោជន៍នានា
- ហានិភ័យនៃការទន្ទ្រានរបស់ក្រុមមនុស្សអភិជន



# ហានិភ័យបរិស្ថាន





① ហានិភ័យនៃបំលាស់ប្តូរព្រៃធម្មជាតិទៅជាព្រៃដាំ



③ ហានិភ័យនៃការលិចធ្លាយ

② ហានិភ័យនៃការបាត់បង់ព្រៃឈើបន្ទាប់ពីទទួលបានពីការទូទាត់ឥណទានកាបូន

# សេចក្តីសម្រេចសំខាន់ៗរបស់UNFCCC ស្តីពីប្រព័ន្ធធានា សុវត្ថិភាពរេដបូក

- ប្រព័ន្ធធានាសុវត្ថិភាព ខេនខូន Cancun (សេចក្តីសម្រេច 1/CP.16)
- សេចក្តីណែនាំ ដឺបេនDurban (សេចក្តីសម្រេច 12/CP.17)
- ក្របខណ្ឌការងារ Warsaw (សេចក្តីសម្រេច 12/CP.19)










យន្តការសម្របសម្រួលថ្នាក់ជាតិ
យុទ្ធសាស្ត្ររេដបូកជាតិ (NRS)
ប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិ (NFMS)
ប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក (SIS)
កម្រិតបំភាយយោងព្រៃឈើ (FREL/REL)

# កិច្ចព្រមព្រៀង Cancun (សេចក្តីសម្រេចចិត្ត១/ CP.១៦)

ពេលដែលដំណើរការសកម្មភាពរេដបូក យោងទៅក្នុងកថាខ័ណ្ឌ ៧០ ការធានាសុវត្ថិភាពដូចខាងក្រោមនេះគួរតែត្រូវបានលើកកម្ពស់:

ក. បំពេញបន្ថែម ឬស្របទៅនឹង គោលបំណងកម្មវិធីព្រៃឈើជាតិ និងអនុសញ្ញាអន្តរជាតិ

ខ. រចនាសម្ព័ន្ធអភិបាលកិច្ចមានតម្លាភាព និងមានប្រសិទ្ធិភាព ដែលគិតពីច្បាប់ និងអធិបតេយ្យភាពជាតិ

គ. គោរពចំពោះចំណេះដឹង និងសិទ្ធិរបស់ជនជាតិដើមភាគតិច និងសមាជិកសហគមន៍មូលដ្ឋាន



# កិច្ចព្រមព្រៀង ខេនខូន (សេចក្តីសម្រេចចិត្ត១/ CP.១៦)

ឃ. ការចូលរួម**ពេញលេញនិងមានប្រសិទ្ធិភាព**របស់ស្ថាប័នពាក់ព័ន្ធ ជាពិសេសជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋាន

ង. ស្របជាមួយនឹងការ**អភិរក្សព្រៃធម្មជាតិ និងភាពសម្បូរបែបជីវសាស្ត្រ**

ច. សកម្មភាពដើម្បីដោះស្រាយហានិភ័យនៃ**បញ្ហាដែលកើតឡើងវិញ**

ឆ. សកម្មភាពដើម្បីកាត់បន្ថយ **ការផ្លាស់ទីរបស់ការបំភាយឧស្ម័ន**



# គោលបំណងសំខាន់ៗនៃប្រព័ន្ធធានាសុវត្ថិភាពរេដបូក

## នៅកម្រិតអប្បរមា

- កំណត់ហានិភ័យអវិជ្ជមាននៃសកម្មភាពរេដបូក
- រកដំណោះស្រាយ ដើម្បីបញ្ចៀស ឬ កាត់បន្ថយហានិភ័យអវិជ្ជមាន

## ប៉ុន្តែថែមទាំង,

- រេដបូកអាចផ្តល់នូវពហុប្រយោជន៍ដល់សង្គម និងបរិស្ថាន

- ប្រព័ន្ធធានាសុវត្ថិភាពរេដបូក នឹងចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។



# ការរៀបចំប្រព័ន្ធការធានាសុវត្ថិភាព (SIS)

1. កំណត់ហានីភ័យ ដែលចេញពីការអនុវត្តយុទ្ធសាស្ត្ររេដបូក

2. កំណត់ គោលនយោបាយ ច្បាប់ និង បទបញ្ញត្តិ សម្រាប់ដោះហានីភ័យខាងលើ (PLR)

3. ការបង្កើតសូចនាករ វិធីសាស្ត្រសម្រាប់ប្រមូលវិភាគទិន្នន័យ និង ការកំណត់ពីការទទួលខុសត្រូវរបស់ស្ថាប័នក្នុងការផ្តល់ព័ត៌មាន (SIS)។



# ការរៀបចំប្រព័ន្ធធានាសុវត្ថិភាពរេដបូក នៃយុទ្ធសាស្ត្ររេដបូកជាតិ



## ១. ការបង្កើតវិធីសាស្ត្រជាតិសម្រាប់ប្រព័ន្ធសុវត្ថិភាពក្រុងកាន់គុន

គោលការណ៍ និងលក្ខណៈវិនិច្ឆ័យសម្រាប់ប្រព័ន្ធសុវត្ថិភាពរេដបូកនៅកម្ពុជា៖

- ការប្រជុំពិគ្រោះយោបល់នៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិជាមួយអ្នកពាក់ព័ន្ធ**សរុបចំនួន ៣១៧នាក់** **គោលនយោបាយ ច្បាប់ និង បទបញ្ញត្តិ សម្រាប់ដោះហានីភ័យខាងលើ (PLR) និង** **សូចនាករ វិធីសាស្ត្រសម្រាប់ប្រមូល វិភាគទិន្នន័យ**



## ២. សំណើសូចនាករដំបូង និងប្រភពទិន្នន័យសម្រាប់ SIS របស់កម្ពុជា

កម្ពុជាបានស្នើនូវសំណុំសូចនាករដំបូង និងប្រភពទិន្នន័យសម្រាប់**តាមដាន និងរាយការណ៍** អំពីថាតើប្រព័ន្ធសុវត្ថិភាពត្រូវបានដោះស្រាយ និង គោរពតាមបានដោយរបៀបណា នៅទូទាំងការអនុវត្តយុទ្ធសាស្ត្រយុទ្ធសាស្ត្ររេដបូជាតិ។



## ជំហានទី ១ (២០១៥-២០១៦)

- <u>រៀបចំកែសម្រួល និងធ្វើអោយប្រសើរឡើងនូវប្រព័ន្ធសុវត្ថិភាព៖</u>

១. កែសម្រួល**<u>គោលការណ៍ និងលក្ខណៈវិនិច្ឆ័យ</u>**សម្រាប់ប្រព័ន្ធសុវត្ថិភាពរេដបូក

២. ការផ្សារភ្ជាប់គោលការណ៍ និងលក្ខណៈវិនិច្ឆ័យទាំងនេះជាមួយគោលនយោបាយ និងវិធានការដាក់លាក់ (*ដែលមានស្រាប់ក្នុងប្រទេសកម្ពុជា*)

៣. ធ្វើការពិនិត្យស្ថានភាពច្បាប់នៃ**<u>គោលការណ៍ និងលក្ខណៈវិនិច្ឆ័យ</u>**ដែលបានកែសម្រួលដើម្បីធានាឲ្យមានស្របគ្នាជាមួយច្បាប់របស់កម្ពុជា។

បង្កើតជម្រើសសម្រាប់ក្របខ័ណ្ឌ ប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក (SIS)៖ កិច្ចការនេះទាក់ទងនឹង៖

1. សំណើឲ្យមាន**សូចនាករ**ចុងក្រោយ **ប្រភពទិន្នន័យ និងវិធីប្រមូលទិន្នន័យ** អំពីលទ្ធភាព និងភាពជាក់ស្តែងនៃការអនុវត្ត និង

2. **ការកំណត់អត្តសញ្ញាណស្ថាប័ន**(ដែលមានស្រាប់ និង/ឬ ថ្មី) និងយន្តការសម្របសម្រួល ដើម្បីប្រមូល វិភាគ តាមដាន រៀបចំទុកដាក់ និងរាយការណ៍/ផ្សព្វផ្សាយព័ត៌មានអំពីប្រព័ន្ធសុវត្ថិភាព

3. សំណើទាំងនេះនឹងត្រូវរៀបចំឡើង ក្រោមការសម្របសម្រួលជិតស្និទ្ធជាមួយព័ត៌មានអំពី MRV, សារពើភណ្ឌព្រៃឈើជាតិ (NFI) និង ប្រព្រួតពិនិត្យព្រៃឈើជាតិ (NFMS)។

## ដំណាក់កាលទី ២ (ពីឆ្នាំ ២០១៧ ដល់ ២០២០)

**ការបង្កើតយន្តការដោះស្រាយដោះស្រាយទំនាស់៖**

នៅក្នុងករណីនៃការរំលោភលើប្រព័ន្ធសុវត្ថិភាព រាជរដ្ឋាភិបាលកម្ពុជាត្រូវចាត់វិធានការសមស្រប និងជាបន្ទាន់។

- បណ្ដុះបណ្ដាលដល់មន្ត្រីពាក់ព័ន្ធដែលទទួលបន្ទុកការងារ SIS។
- សាកល្បង SIS ដំបូង និងប្រមូលយកលទ្ធផលនៃ SIS ដំបូង។

អរគុណ !

Empowered lives.
Resilient nations.

# ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាត

## សេចក្តីព្រាងលើកទី ៤

កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិ ស្តីពីយុទ្ធសាស្ត្ររេដបូកជាតិ
សៀមរាប ថ្ងៃទី២៩ ដល់៣០ ខែកញ្ញា ឆ្នាំ២០១៥

# ដំណាក់កាលសម្រាប់ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ

## នៅរយៈពេលខ្លីចំពោះមុខ (ឆ្នាំ ២០១៦)៖ ការរៀបចំផែនការសកម្មភាពរេដបូក

- រៀបចំផែនការសកម្មភាពពិស្តារ (ឆ្នាំ ២០១៦-២០២០)
- ការរៀបចំស្ថាប័ន និងហិរញ្ញវត្ថុសម្រាប់ការអនុវត្តយុទ្ធសាស្ត្រ និងបង្កើតក្របខ័ណ្ឌជាតិសម្រាប់ M&E
- សកម្មភាពដទៃទៀតដែលត្រូវសម្រេចឲ្យបាន រួមមាន៖
  1. សំណើសម្រាប់ការរៀបចំ NFMS របស់កម្ពុជា សម្រាប់ MRV នៅថ្នាក់ជាតិ
  2. សំណើដើម្បីរៀបចំ FREL/ FRL សម្រាប់កម្ពុជា
  3. ការរៀបចំ និងការសាកល្បងអនុវត្តជាដំបូងនូវ NFMS, SIS, និង FREL/ FRL



# នៅក្នុងរយៈពេលមធ្យម (ឆ្នាំ ២០១៦-២០២០)៖ ការអនុវត្តផែនការសកម្មភាពរេដបូក

- កត្តាជាអាទិភាពដែលត្រូវដោះស្រាយនៅក្នុងរយៈពេល០៥ឆ្នាំខាងមុខ សម្រេចសម្រេចបាន តាមរយៈការពង្រឹងការអនុវត្តកម្មវិធីគ្រប់គ្រងព្រៃឈើដែលមានស្រាប់របស់កម្ពុជា **ដូចជា NFP, NPASMP, SPFF, និង អនុក្រឹត្យស្តីពី ELCs/ SLCs**។

- ទាក់ទងនឹងលក្ខខណ្ឌបច្ចេកទេសដើម្បីកម្ពុជាត្រៀមខ្លួនសម្រាប់ RBP នៅក្រោមរេដបូក រហូតដល់ឆ្នាំ ២០២០ កម្ពុជាត្រូវតែមាន **NFMS, FREL/ FRL និង SIS** ដែលអាចដំណើការបានពេញលេញ ដែលអាចគណនាបរិមាណនៃការបំភាយដែលបានកាត់បន្ថយ ការបាត់បង់ព្រៃឈើ និងថយចុះនៃព្រៃឈើ ។



## នៅក្នុងរយៈពេលមធ្យម (ឆ្នាំ ២០១៦-២០២០)៖
## ការអនុវត្តផែនការសកម្មភាពរេដបូក

ដើម្បីធ្វើបែបនេះបាន សកម្មភាពដូចតទៅនេះ នឹងត្រូវតែបានដាក់ឲ្យអនុវត្តនៅមុនឆ្នាំ ២០២០៖

១.រៀបចំគោលនយោបាយ ស្តង់ដារ និងយន្តការនានាដែលទាក់ទងនឹងសកម្មភាព MRV។ ឯកសារ និងយន្តការនានាទាំងនេះ រួមបញ្ចូលការសម្របសម្រួលស្ថាប័ន និងការចែករំលែកទិន្នន័យ ការធ្វើសុខដុម្មនីយកម្មទិន្នន័យ ការធានាគុណភាព និងវិធានការត្រួតពិនិត្យ ការផ្តល់សុពលភាពលើការគណនាបរិមាណឧស្ម័នផ្ទះកញ្ចក់។

២.ប្រមូលផ្តុំព័ត៌មានពីសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់នៅកម្រិតជាតិសម្រាប់វិស័យព្រៃឈើ និងការប្រើប្រាស់ដីនៅកម្ពុជា ដើម្បីគណនាឥទ្ធិពលពីការកាត់បន្ថយ ដែលកើតចេញពីការអនុវត្តសកម្មភាពរេដបូកនៅកម្រិតជាតិ។



៣. បង្កើតយន្តការចែកចាយព័ត៌មាន សម្រាប់ការគ្រប់គ្រង និងរៀបចំទិន្នន័យ ភូមិសាស្ត្រ និងទិន្នន័យ ដទៃទៀត សម្រាប់អ្នកពាក់ព័ន្ធនានាយកទៅប្រើប្រាស់។

៤. ចាត់ចែងឲ្យមានភាពបំពេញគ្នារវាង NFMS ជាមួយប្រព័ន្ធ ព័ត៌មានសម្រាប់ សុវត្ថិភាពរេដបូក។

៥. នៅក្នុងប្រតិបត្តិការ NFMS ត្រូវធានាឲ្យមានទិន្នន័យសុក្រិតអំពីការប្រែប្រួលនៃការប្រើប្រាស់ដីព្រៃនិងផលប៉ះពាល់មកលើស្តុកកាបូន និងមុខងារផ្សេងទៀតនៃប្រព័ន្ធអេកូឡូស៊ី។



៦. ប្រមូលផ្តុំទិន្នន័យពាក់ព័ន្ធ និងរបាយការណ៍ពីលទ្ធផលនានាដែលបានពីការអនុវត្តរេដបូក ទៅលេខាធិការដ្ឋានអនុសញ្ញា UNFCCC តាមរយៈឧបសម្ព័ន្ធបច្ចេកទេសមួយភ្ជាប់ជាមួយរបាយការណ៍បច្ចុប្បន្នភាពប្រចាំពីរឆ្នាំម្តងរបស់កម្ពុជា (BUR)។

៧. កសាងសមត្ថភាពសម្របសម្រួលក្នុងចំណោមអ្នកអនុវត្ត NFMS, SIS និងFREL/ FRL នៅក្នុងស្ថាប័នរេដបូកដែលពាក់ព័ន្ធ។



## នៅក្នុងរយៈពេលវែង(ក្រោយឆ្នាំ ២០២០)៖ ដំណាក់កាលនៃការទូទាត់ដែលផ្អែកលើលទ្ធផល

1. នៅដើមឆ្នាំ ២០២១ វិធី NFMS, FREL/ FRL និង SIS និងទិន្នន័យនានា នឹងត្រូវបានកែលម្អរួចទៅហើយ ដូច្នេះយុទ្ធសាស្ត្រ NRS នឹងអាចពង្រីក ។

2. នៅក្នុងរយៈពេលមួយឆ្នាំមុនចុងបញ្ចប់នៃដំណាក់កាលអនុវត្ត គេត្រូវធ្វើការវាយតម្លៃដោយឯករាជ្យ និងពេញលេញ អំពីភាពខ្លាំង ភាពទន់ខ្សោយ ឱកាស និងការគំរាមកំហែង(SWOT) សម្រាប់យុទ្ធសាស្ត្រ NRS, NFMS, FREL/ FRL, និង SIS។

3. លើសពីនេះ គេចាំបាច់ត្រូវធ្វើការសិក្សាបន្ថែមទៀតអំពីកត្តានានានៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ ការគណនាកត្តាទាំងនេះ ដោយគិតជាបរិមាណនៃការបំភាយកាបូន ការចាត់កត្តាសំខាន់ៗជាអាទិភាព ដើម្បីដោះស្រាយនៅក្រោយឆ្នាំ ២០២០.



អរគុណ !